ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី 22 ខែ មេសា ឆ្នាំ២០១៦។

ADB **ធនាគារអភិវឌ្ឍន៍អាស៊ី**

## ប្រទេសកម្ពុជា ៖ កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| លេខគម្រោង | 49041-001 |
| ប្រទេស | កម្ពុជា |
| ស្ថានភាពគម្រោង | អនុម័ត |
| ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ | ជំនួយបច្ចេកទេស |
| ប្រភពមូលនិធិ/ចំនួនទឹកប្រាក់ | TA 9069-CAM ៖ កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>មូលនិធិពិសេសសម្រាប់ជំនួយបច្ចេកទេស ៦០០.០០០ ដុល្លារអាមេរិក |
| របៀបវារៈយុទ្ធសាស្ត្រ | កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយផ្អែកចំណេះដឹង |
| វិស័យ/អនុវិស័យ | **ការគ្រប់គ្រងវិស័យសាធារណៈ** ៖ ចំណាយសាធារណៈ និងការគ្រប់គ្រងសារពើពន្ធ |
| សមធម៌យេនឌ័រ និងការបញ្រ្ជាបយេនឌ័រ | ធាតុផ្សំយេនឌ័រមួយចំនួន |
| ការពណ៌នា | ផលប៉ះពាល់រំពឹងទុក គឺជាការកែលម្អសេវាសាធារណៈ ដែលផ្តោតលើក្រុមជនក្រីក្រ និងងាយរងគ្រោះ ស្របតាមគោលបំណងរបស់រាជរដ្ឋាភិបាល សម្រាប់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)។ លទ្ធផល |

| | |
|---|---|
| | រំពឹងទុក គឺជាការពង្រឹងការឃ្លាំមើលទៅលើចំណាយសាធារណៈ ដែលត្រូវសម្រេចឱ្យបានតាមរយៈធាតុចេញចំនួន៣។ ធាតុចេញទី១ គឺជាការពង្រឹងក្របខ័ណ្ឌ និងប្រព័ន្ធគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើការគ្រប់គ្រងបំណុលសាធារណៈ ការរៀបចំថវិកាកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ និង សវនកម្មផ្ទៃក្នុង។ ធាតុចេញទី២ នឹងផ្តោតលើការពង្រឹងការរៀបចំថវិកាកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ និង សវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួងពាក់ព័ន្ធមួយចំនួនដែលត្រូវបានជ្រើសរើស។ ធាតុចេញទី៣ គឺជាការពង្រឹងសវនកម្មខាងក្រៅ ដើម្បីកែលម្អគណនេយ្យភាពសម្រាប់ចំណាយសាធារណៈ។ កម្មវិធីនេះ នឹងគាំទ្រដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុម័ត និងអនុវត្តគោលនយោបាយ និង កំណែទម្រង់លិខិតបទដ្ឋានគតិយុត្តិ ព្រមទាំងការអនុវត្តន៍កំណែទម្រង់ទាំងនោះ នៅតាមបណ្តាក្រសួងតាមវិស័យសំខាន់ៗមួយចំនួនដែលត្រូវបានជ្រើសរើស។ ការរចនាបឋម និងក្របខ័ណ្ឌត្រួតពិនិត្យ ព្រមទាំងដើមឈើបញ្ហា មាននៅក្នុងឧបសម្ព័ន្ធ១ និង ២។ |
| **វិចារណភាពគម្រោង និង ការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រ ប្រទេស/តំបន់** | បញ្ហាការអភិវឌ្ឍន៍ ៖ ភាពខុសគ្នាចំពោះកម្រិតភាពក្រីក្រ រវាងតំបន់ជនបទ និងតំបន់ទីក្រុង។ អត្រាភាពក្រីកបានធ្លាក់ចុះពី ៤៧,៨% ក្នុងឆ្នាំ២០០៧ មក ១៨,៩% (១៤,៥៥% នៅតំបន់ទីក្រុង និង ១៩,៩% នៅតំបន់ជនបទ) ក្នុងឆ្នាំ ២០១២។ បញ្ហាប្រឈមដែលនៅសេសសល់ រួមមាន កំណើនភាគរយនៃគ្រួសារក្រីក្រនៅតំបន់ជនបទ (កើនឡើងពី៨៩% ក្នុងឆ្នាំ២០០៤ ទៅ ៩១% ក្នុងឆ្នាំ២០១១) បើទោះបីជាអត្រាភាពក្រីក្រមាននិន្នាការធ្លាក់ចុះជារួមក៏ដោយ។ ឧបសគ្គរាំងស្ទះក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា រួមមាន អភិបាលកិច្ចទន់ខ្សោយ សេវាសាធារណៈមិនល្អ កាលានុវត្តភាពការងារផលិតកម្មមានកម្រិតជំនាញទាប និង សំណាញ់សុវត្ថិភាពសង្គមមិនគ្រប់គ្រាន់។<br><br>ឧបសគ្គរាំងស្ទះរួមបញ្ចូលគ្នា ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទន់ខ្សោយ និងការផ្តល់សេវាសាធារណៈមិនគ្រប់គ្រាន់។ ការកាត់បន្ថយភាពក្រីក្រ ទាមទារឱ្យមានការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ដែលអាចកែលម្អបានតាមរយៈវិភាជន៍ថវិកា ការប្រតិបត្តិ និងគណនេយ្យភាព ឱ្យបានកាន់តែប្រសើរជាងនេះ។ ចំណូលកំពុងមានភាពប្រសើរឡើងបន្តិចម្តងៗ (ប៉ាន់ប្រមាណត្រឹម ១៤,៤% នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០១៤) ប៉ុន្តែបើទោះជាដូច្នេះក្តី ក៏នៅតែមានកម្រិតទាប។ ក្របខ័ណ្ឌ និងប្រព័ន្ធនិយ័តកម្មសម្រាប់ |

ការរៀបចំថវិកាកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ការគ្រប់គ្រងបំណុលសាធារណៈ និង សវនកម្មខាងក្នុង និងខាងក្រៅ មិនទាន់ត្រូវបានអភិវឌ្ឍន៍ឱ្យបានគ្រប់គ្រាន់នៅឡើយ។ វិភាជន៍ថវិកា ពុំមានសង្គតភាពទាំងស្រុងទៅនឹងគោលនយោបាយតាមវិស័យ សម្រាប់ការកំណត់គោលដៅជនក្រីក្រឱ្យបានកាន់តែប្រសើរនៅឡើយ។ សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្មខាងក្នុង និងខាងក្រៅ កំពុងមានភាពប្រសើរឡើងបន្តិចម្តងៗ ប៉ុន្តែ វានៅតែបន្តមានភាពមិនគ្រប់គ្រាន់។ ភាពទន់ខ្សោយទាំងនេះ បង្កឱ្យមានហានិភ័យសន្យាធានាគួរឱ្យកត់សម្គាល់ ដែលត្រូវបានសង្កត់ធ្ងន់ដោយភាពគ្មានប្រសិទ្ធភាពក្នុងការវិភាជន៍បែងចែក និងភាពទន់ខ្សោយនៃគណនេយ្យភាពចំពោះចំណាយសាធារណៈ។

យុទ្ធសាស្ត្រតាមវិស័យរបស់រាជរដ្ឋាភិបាល ៖ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ត្រូវបានអនុវត្ត ដើម្បីពង្រឹងទៅលើការឃ្លាំមើលចំណាយសាធារណៈ សំដៅធ្វើឱ្យសេវាសាធារណៈមានភាពប្រសើរឡើង ជាពិសេស សេវាទាំងឡាយណាដែលកំណត់គោលដៅចំពោះជនក្រីក្រ។ ស្ថិតក្រោមដំណាក់កាលទី១ និង ដំណាក់កាលទី២ គេសម្រេចបានវឌ្ឍនភាពមួយចំនួនក្នុងការកែលម្អភាពគួរឱ្យជឿជាក់បាននៃថវិកា ព្រមទាំងណែនាំនូវប្រព័ន្ធបែងចែកចំណាត់ថ្នាក់ថវិកាថ្មីមួយ និងតារាងគណនីថ្មី។ គេក៏សម្រេចបាននូវវឌ្ឍនភាពមួយចំនួនផងដែរ នៅក្នុងការគ្រប់គ្រងបំណុលសាធារណៈ កិច្ចលទ្ធកម្ម និងសវនកម្មខាងក្នុង និងខាងក្រៅ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIF) នៅឯក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) បានមានប្រតិបត្តិការចាប់ពីខែកក្កដា ឆ្នាំ២០១៥ មក។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពង្រឹង និងធ្វើការប្រែបាច់បញ្ចូលគ្នានូវគោលនយោបាយ ក្របខ័ណ្ឌស្ថាប័ន និងការអភិវឌ្ឍន៍សមត្ថភាព ក្រោមដំណាក់កាលទាំងពីរកន្លងមក នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយបច្ចុប្បន្ន កំពុងធ្វើការរៀបចំត្រៀមលក្ខណៈសម្រាប់ដំណាក់កាលទី៣។

អន្តរាគមន៍ និងមេរៀនបទពិសោធន៍កន្លងមករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ៖ ផ្សព្វផ្សាយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនដល់បណ្តាក្រសួងពាក់ព័ន្ធ។ កម្រងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលទទួលបានហិរញ្ញប្បទានគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី បានគាំទ្រដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុវត្តន៍ដំណាក់កាលទី២។ សកម្មភាពនេះ រាប់បញ្ចូល

បទប្បញ្ញត្តិ និងវិធានការសំខាន់ៗ ដើម្បីពង្រឹងក្របខ័ណ្ឌគតិយុត្តិ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ កិច្ចលទ្ធកម្មទំនិញ និងសេវាកម្ម សម្រាប់គម្រោងដែលទទួលបានហិរញ្ញប្បទានគាំទ្រពីខាងក្រៅ ការគ្រប់គ្រងហិរញ្ញវត្ថុ សវនកម្មខាងក្នុង និង ការងារឆ្ពោះទៅមុខ ស្តីពីការរៀបចំថវិកាកម្មវិធីដែលស្ថិតក្រោមដំណាក់កាលទី៣។ កម្រងកម្មវិធីក៏បានគាំទ្រដល់ការអនុវត្តន៍ដំណាក់កាលទី២នៅតាមក្រសួងអភិវឌ្ឍន៍ជនបទ (RDMs) ចំនួន ៣ ផងដែរ។ បន្ថែមពីនេះទៀតធនាគារអភិវឌ្ឍន៍អាស៊ី បានគាំទ្រដល់អាជ្ញាធរសវនកម្មជាតិ (NAA) ក្នុងការអនុវត្តន៍បទដ្ឋានអន្តរជាតិ សម្រាប់ស្ថាប័នសវនកម្មជាន់ខ្ពស់។

ការធានាឱ្យមាននិរន្តរភាពកិច្ចគាំទ្រចំពោះវឌ្ឍនភាពនៃកំណែទម្រង់ជារួម ៖ កម្មវិធីដែលបានស្នើឡើងធ្វើការច្របាច់បញ្ចូលគ្នានូវកិច្ចគាំទ្រពីក្រោមទៅលើ ជូនដល់ក្រសួងពាក់ព័ន្ធសំខាន់ៗជាមួយនឹងកិច្ចគាំទ្រ សម្រាប់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកាន់តែមានភាពទូលំទូលាយជាងនេះ។ សមិទ្ធិផលបឋមចំពោះភាពគួរឱ្យជឿជាក់បាននៃថវិកា និងគណនេយ្យភាព ការគ្រប់គ្រងបំណុលសាធារណៈ និងការតភ្ជាប់គោលនយោបាយថវិកា ដែលមានភាពប្រសើរជាងមុន ព្រមទាំងការពង្រឹងស្ថាប័នរបស់អាជ្ញាធរសវនកម្មជាតិ ត្រូវធ្វើឱ្យមាននិរន្តរភាព និងពង្រឹងបន្ថែម។

ការពង្រឹងទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមបណ្តាក្រសួងពាក់ព័ន្ធសំខាន់ៗ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីកែលម្អសេវាសាធារណៈ។ RDMs ទាំង៣ មានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈ។ កិច្ចគាំទ្របន្ថែមទៀតសម្រាប់ក្រសួងទាំងនេះ និង ការពង្រីកកម្មវិធីដែលបានស្នើឡើងទៅកាន់ក្រសួងចំនួន ៣ បន្ថែមទៀត និង ជួយពង្រឹងក្របខ័ណ្ឌ និងសមត្ថភាពស្ថាប័នរបស់ពួកគេនៅក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសំខាន់ៗ។

ការសម្របសម្រួលជាមួយអន្តរាគមន៍ដែលមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ ៖ គេនឹងធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលរួមមានជាអាទិ៍ EU , GIZ , ស៊ុយអែត , IMF , អង្គការសហប្រជាជាតិ និងធនាគារពិភពលោក។

គំរូកម្មវិធី ៖ អន្តរាគមន៍ដែលបានស្នើឡើង ដែលជាកម្មវិធីមួយមានមូលដ្ឋានផ្អែកលើគោលនយោបាយ រួមមានអនុកម្មវិធីចំនួន២។

ផលប៉ះពាល់

## លទ្ធផលគម្រោង

ការពណ៌នាអំពីលទ្ធផល

វឌ្ឍនភាពឆ្ពោះទៅរកលទ្ធផល

## វឌ្ឍនភាពនៃការអនុវត្តន៍

ការពណ៌នាអំពីទិន្នផលគម្រោង

ស្ថានភាពនៃវឌ្ឍនភាពអនុវត្ត (ទិន្នផល សកម្មភាព និង បញ្ហា)

ទីតាំងភូមិសាស្ត្រ

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

ទិដ្ឋភាពផ្នែកបរិស្ថាន

ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត

ជនជាតិដើមភាគតិច

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្នុងអំឡុងពេលនៃការរៀបចំគម្រោង

ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង

## បុគ្គលិកទទួលខុសត្រូវ

| | |
|---|---|
| **មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ** | អ៊ូច ចំរើន |
| **នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ** | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| **ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ** | និវាសដ្ឋានបេសកម្មប្រចាំប្រទេសកម្ពុជា |

| | |
|---|---|
| ទីភ្នាក់ងារប្រតិបត្តិ | ធនាគារអភិវឌ្ឍន៍អាស៊ី<br>លោក Samiuela T. Tukuafu នាយកប្រចាំប្រទេស<br>និវាសដ្ឋានបេសកម្មប្រចាំប្រទេសកម្ពុជា<br>6 ADB Avenue, Mandaluyong City 1550, Philippines |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | - |
| បេសកកម្មស្វែងរកការពិត | - |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង (MRM) | - |
| ការអនុម័ត | ១៤ មករា ២០១៦ |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ០១ កុម្ភៈ ២០១៦ |

TA 9069-CAM៖ កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ព្រឹត្តិការណ៍សំខាន់ៗ

| ការអនុម័ត | ការចុះហត្ថលេខា | ការចូលជាធរមាន | ការបិទ | | |
|---|---|---|---|---|---|
| | | | កំណត់ពីដំបូង | កែសម្រួលឡើងវិញ | ជាក់ស្តែង |
| ១៤ មករា ២០១៦ | ២២ មីនា ២០១៦ | ២២ មីនា ២០១៦ | ៣១ ធ្នូ ២០១៦ | - | - |

| ផែនការផ្តល់ហិរញ្ញប្បទាន/ការប្រើប្រាស់ TA | | | | | | | ការដក សាច់ប្រាក់សរុប | |
|---|---|---|---|---|---|---|---|---|
| ADB | សហហិរញ្ញប្បទាន | សមភាគី | | | | សរុប | កាលបរិច្ឆេទ | ចំនួនទឹកប្រាក់ |
| | | រដ្ឋាភិបាល | អ្នកទទួលផល | អ្នកឧបត្ថម្ភគម្រោង | ផ្សេងៗ | | | |
| 600,000.00 | 0.00 | 100,000.00 | 0.00 | 0.00 | 0.00 | 700,000.00 | ១៤ មករា ២០១៦ | 0.00 |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។